ក

មាតិកា

I.ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

២២-៤-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៤០៧/១៤៩ ស្តីពីការប្រោសព្រះរាជទានជាកិច្ចបច្ឆាមរណៈចំពោះ ឯកឧត្តម **ស ភាពុន** នូវ គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា ៣២៧៧

២២-៤-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៤០៧/១៥០ ស្តីពីការប្រោសព្រះរាជទាន ចំពោះ លោកជំទាវ **ឆាន ស្រីមុំ** នូវ គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ៣២៧៨

២២-៤-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៤០៧/១៥២ ស្តីពីការប្រោសព្រះរាជទាន នូវ គ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ឯកឧត្តម ចំនួន ០៨ រូប ៣២៧៩

២៥-៤-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៤០៧/១៥៣ ស្តីពីការប្រោសព្រះរាជទាន នូវ គ្រឿង ឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា ចំពោះ ឧកញ៉ា **លីម ហ៊ុយឡេង** ៣២៨០

II.រាជរដ្ឋាភិបាល

១.អនុក្រឹត្យ

២៣-៤-២០០៧ -អនុក្រឹត្យលេខ ៣៤ អនក្រ.បក ស្តីពីការកែសម្រួល ផ្នែកទី ១ ឧបសម្ព័ន្ធទី ១ នៃអនុក្រឹត្យលេខ ១១១ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៥ ស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ៣២៨១

២៤-៤-២០០៧ -អនុក្រឹត្យលេខ ៣៥ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ៣២៨៣

២៣-៤-២០០៧ -អនុក្រឹត្យលេខ ៣៣៩ អនក្រ.តត ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៣២៨៥

២៣-៤-២០០៧ -អនុក្រឹត្យលេខ ៣៤០ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៣២៨៦

២៣-៤-២០០៧ -អនុក្រឹត្យលេខ ៣៤១ អនក្រ.តត ស្តីពីការលុបឈ្មោះមន្ត្រីរាជការក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ៣២៨៧

២៤-៤-២០០៧ -អនុក្រឹត្យលេខ ៣៨២ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៣២៨៨

២៥-៤-២០០៧ -អនុក្រឹត្យលេខ ៣៨៣ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ និងមេដាយការងារ ៣២៨៩

២៧-៤-២០០៧ -អនុក្រឹត្យលេខ ៣៨៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣២៩២

២.សេចក្តីសំរេច

២៣-៤-២០០៧ -សេចក្តីសំរេចលេខ២១ សសរ ស្តីពីការបង្កើតគណៈកម្មការវាយតម្លៃ និងរៀបចំបែងចែកដី ចំពោះគម្រោងអភិវឌ្ឍន៍របស់ក្រុមហ៊ុន កំពត ផត ៣២៩៤

៣.សារាចរណែនាំ

២៥-៤-២០០៧ -សារាចរណែនាំលេខ០២ សរ ណន ស្តីពីការចាត់តាំងខួបអនុស្សាវរីយ៍លើកទី ១២១ នៃទិវាពលកម្មអន្តរជាតិ ថ្ងៃទី ១ ខែ ឧសភា ឆ្នាំ ២០០៧ ៣២៩៦

III.ការងារបណ្តាក្រសួង

១.ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

១៦-៣-២០០៧ -ប្រកាសលេខ ៣៩៦ អយក.ប្រក ស្តីពីការពង្រីកសាលារៀនចំណេះទូទៅឯកជន " **សាលាអន្តរជាតិញូវយ៉ក** " ស្ថិតនៅក្នុង សង្កាត់ បឹងកក់ ២ ខណ្ឌ ទួលគោក រាជធានីភ្នំពេញ ៣២៩៨

២៧-៣-២០០៧ -ប្រកាសលេខ ៤៥៧ អយក.ប្រក ស្តីពីការប្តូរឈ្មោះ អនុវិទ្យាល័យ " **ជន្លង់ខ្មួ** " ទៅជាអនុវិទ្យាល័យ " **ហ៊ុន សែន ជន្លង់ខ្មួ** " ស្ថិតនៅក្នុង សង្កាត់ ភ្លើងឆេះរទេះ ខណ្ឌ ដង្កោ រាជធានីភ្នំពេញ ៣៣០០

២៧-៣-២០០៧ -ប្រកាសលេខ ៤៥៨ អយក.ប្រក ស្តីពីការពង្រីកសាលារៀនចំណេះទូទៅឯកជន " **សាលារៀន អន្តរទ្វីបអាមេរិកកាំង** " ស្ថិតនៅក្នុង សង្កាត់ ទួលស្វាយព្រៃ ទី ១ ខណ្ឌ ចំការមន ក្រុងភ្នំពេញ ៣៣០១

២៧-៣-២០០៧ -ប្រកាសលេខ ៤៥៩ អយក.ប្រក ស្តីពីការពង្រីកអនុវិទ្យាល័យ " **ហ៊ុន សែន កំពង់សិលា** " ទៅជាវិទ្យាល័យ " **ហ៊ុន សែន កំពង់សិលា** " ស្ថិតនៅក្នុង ឃុំ កំពង់សិលា ស្រុកកំពង់សិលា ខេត្ត កោះកុង ៣៣០៣

២៧-៣-២០០៧ -ប្រកាសលេខ ៤៦០ អយក.ប្រក ស្តីពីការប្តូរឈ្មោះ វិទ្យាល័យ " **អួន ពំនួមុនីវត្ត វិហារសួគ៌** " ទៅជាវិទ្យាល័យ " **វិហារសួគ៌** " ស្ថិតនៅក្នុង ឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ៣៣០៤

២៧-៣-២០០៧ -ប្រកាសលេខ ៤៦១ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ " **ស្វាយរលំ** " ស្ថិតនៅក្នុង ឃុំស្វាយរលំ ស្រុក ស្អាង ខេត្តកណ្តាល ៣៣០៥

២៧-៣-២០០៧ -ប្រកាសលេខ ៤៦២ អយក.ប្រក ស្តីពីការពង្រីកអនុវិទ្យាល័យ " **ហ្វារពន្លឺសិល្បៈ**" ទៅជាវិទ្យាល័យ " **ហ្វារពន្លឺសិល្បៈ**" ស្ថិតនៅក្នុង ឃុំអូរចារ ស្រុកបាត់ដំបង ខេត្ត បាត់ដំបង ៣៣០៦

២៧-៣-២០០៧ -ប្រកាសលេខ ៤៦៣ អយក.ប្រក ស្តីពីការពង្រីកអនុវិទ្យាល័យ " **ហ៊ុន សែន ព្រៃនប់** " ទៅជាវិទ្យាល័យ " **ហ៊ុន សែន ព្រៃនប់** " ស្ថិតនៅក្នុង សង្កាត់ព្រៃនប់ ខណ្ឌ ព្រៃនប់ ក្រុងព្រះសីហនុ ៣៣០៧

២៧-៣-២០០៧ -ប្រកាសលេខ ៤៦៤ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ " **ប៊ិតត្រាំង** " ស្ថិតនៅក្នុង សង្កាត់ បិតត្រាំង ខណ្ឌ ព្រៃនប់ ក្រុងព្រះសីហនុ ៣៣០៨

២_លិខិតបទដ្ឋានគតិយុត្តក្រសួងពាណិជ្ជកម្ម

១០-០១-២០០៧ -លិខិតបញ្ជាក់លេខ ០១៣៩ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **វ៉ាន់ ឌីវេឡុបមេន** ៣៣០៩

១០-០១-២០០៧ -លិខិតបញ្ជាក់លេខ ០១៤២ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឃ្លាកយូ ទេប ខូ អិលធីឌី** ៣៣១១

១០-០១-២០០៧ -លិខិតបញ្ជាក់លេខ ០១៤៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ញូ សេអ៊ូល ហោម៉្យឹង** ៣៣១៣

១០-០១-២០០៧ -លិខិតបញ្ជាក់លេខ ០១៤៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អ៊ីសឃើន សាន់ មីមឌូ អ៊ិនដាស្ទ្រី** ៣៣១៥

១០-០១-២០០៧ -លិខិតបញ្ជាក់លេខ ០១៤៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេស៊ា ស៊ី.ឌី.អាយ អិចស៊ីម ខូ អិលធីឌី** ៣៣១៧

១០-០១-២០០៧ -លិខិតបញ្ជាក់លេខ ០១៤៩ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អាត្លង់ទិក ស៊ីធី** ៣៣១៩

១០-០១-២០០៧ -លិខិតបញ្ជាក់លេខ ០១៥៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខេមអាហ្សូរ អិលធីឌី** ៣៣២១

១០-០១-២០០៧ -លិខិតបញ្ជាក់លេខ ០១៥៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហ្គោលដែន គ្លរី គ្រុប** ៣៣២៣

១០-០១-២០០៧ -លិខិតបញ្ជាក់លេខ ០១៥៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ធី.ធី. អ៊ិនធើណេសិនណល** ៣៣២៥

១០-០១-២០០៧ -លិខិតបញ្ជាក់លេខ ០១៥៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **នូមេដ (ខេមបូឌា) ខូ អិលធីឌី** ៣៣២៧

១១-០១-២០០៧ -លិខិតបញ្ជាក់លេខ ០១៦៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេ.អិន.អេ.ធួរ សឺវីស** ៣៣២៩

១១-០១-២០០៧ -លិខិតបញ្ជាក់លេខ ០១៦៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេមីច គ្រុប** ៣៣៣១

១១-០១-២០០៧ -លិខិតបញ្ជាក់លេខ ០១៦៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **មេគង្គ ឌិសខាវើរី** ៣៣៣៣

១១-០១-២០០៧ -លិខិតបញ្ជាក់លេខ ០១៦៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ថប ម៉ាស្ទ័រ ស្តារ អ៊ីមផត អិចផត** ៣៣៣៥

១១-០១-២០០៧ -លិខិតបញ្ជាក់លេខ ០១៦៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខេ អេស ជី អេន ជីនារីង** ៣៣៣៧

ព្រះរាជក្រឹត្យ

នស/រកត/០៤០៧/១៤៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពោធគាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ជាកិច្ចបច្ឆាមរណៈ

ចំពោះសព

ឯកឧត្តម ស ភាគុន

នូវ

គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពរល.០៧០៤.១៥៩

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០០៧

លេខ: ១៦៧ ច.ព
ដើម្បីចម្លងចេញ
រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ២០០៧
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ចិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៤០៧/១៥០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរជ្ជបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

លោកជំទាវ ឆាន ស្រីមុំ

នូវ

គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៤.០៧០៤.១៦០

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០០៧

លេខៈ ១៧៦ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ២០០៧
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៤០៧/១៥២

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ :

១-ឯកឧត្តម ចក់ ឡេង
២-ឯកឧត្តម ឃីម បូរ
៣-ឯកឧត្តម ឧត្តមសេនីយ៍ទោ គង់ អៀង

ខ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ចំពោះ :

-ឯកឧត្តម ឧត្តមសេនីយ៍ទោ កៅ ទ្រី

គ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ ចំពោះ :

១-ឯកឧត្តម អ៊ូ សំអួន
២-ឯកឧត្តម ចេង ញ៉ាន់
៣-ឯកឧត្តម ម៉ៅ តិរុណ
៤-ឯកឧត្តម ហេ កាន់

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣/ល.០៧០៤.១៦២

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០០៧

លេខៈ ១៣៦ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ២០០៧
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៤០៧/១៥៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រតនខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមររាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា

ចំពោះ

ឧកញ៉ា លឹម ហ៊ួយឡេង

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៧៧.០៧០៤.១៦៣

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០០៧

លេខ: [illegible] ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ២០០៧
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
ឃុន ជិនកេន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៣៤ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការកែសម្រួល ផ្នែកទី ១ ឧបសម្ព័ន្ធទី ១
នៃអនុក្រឹត្យលេខ ១១១ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៥
ស្តីពី ការអនុវត្តច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជ រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និងព្រះរាជក្រមលេខនស/រកម/០៣០៣/០០៩ ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៤៧ អនក្រ.បក ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញអនុក្រឹត្យលេខ ២៧ អនក្រ.បក ចុះថ្ងៃទី ១៤ ខែមីនា ឆ្នាំ ២០០៦ និងអនុក្រឹត្យលេខ៩២ អនក្រ.បក ចុះថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០០៦ ស្តីពីការកែសម្រួលអនុក្រឹត្យលេ១៤៧ អនក្រ.បក ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

- អនុលោមតាមតម្រូវការចាំបាច់របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

សម្រេច

មាត្រា ១ : ចំណុចទី ៥" សកម្មភាពវិនិយោគផ្សេងៗទៀត ដែលច្បាប់ហាមឃាត់" នៃផ្នែកទី១ ក្នុងឧបសម្ព័ន្ធទី១ នៃ នៃអនុក្រឹត្យលេខ ១១១ អនក្រ.បកចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៥ ស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្ម ច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានលុបចេញ ។

មាត្រា ២ : ក្រៅពីនេះខ្លឹមសារ នៃអនុក្រឹត្យលេខ ១១១ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៥ រួមទាំងឧបសម្ព័ន្ធទាំងអស់ ដែលជាចំណែកភ្ជាប់អនុក្រឹត្យនេះ នៅរក្សាទុកជាធរមានដដែល ។

ត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន អភិបាលគ្រប់ខេត្ត-ក្រុង ពាក់ព័ន្ធទាំងអស់ ដែលជាអនុប្រធាន និងជាសមាជិកនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវទទួលអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែមករា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

បានជម្រាបជូន

សម្តេចនាយករដ្ឋមន្ត្រី

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

គាត ឈន់

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ :..៣៥..អនក្រ.បក

អនុក្រឹត្យ

ស្តីពីការផ្ទេរឥណទានថវិកា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ , ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ , ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ,ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធ ហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០ ន.ស ៩៤ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ , ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៩ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ , ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ ,ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ និងប្រកាសលេខ ១៤០១ សហវ.ប្រក.ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការដាក់អោយអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាទូទៅរបស់រដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ , ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៧
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក , ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែមនិង កែសំរួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៧១ អនក្រ.បក , ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៧
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សម្រេច

មាត្រា១: ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកាចំនួន ៤៨៩.៤៣០.០០០ រៀល (បួនរយប៉ែតសិបប្រាំបួនលានបួនរយសាមសិបពាន់រៀលគត់) ពីជំពូក ០៩ (ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ៦៤ (បន្ទុកបុគ្គលិក) ជូនក្រសួង និង មន្ទីរខេត្ត-ក្រុង ដូចមានតារាងឧបសម្ព័ន្ធភ្ជាប់ជាមួយ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ។

មាត្រា២: ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះ តាមគណនី និង អនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់អនុវត្តកន្សោមអាទិភាពក្នុងឆ្នាំ ២០០៧ ។

មាត្រា៣: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការក្រសួងពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែមេសា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត់ ចាន់ថុល

រដ្ឋមន្ត្រីស្តីទី

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៣៣៩ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្តការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

ស ម្រេ ច

មាត្រា ១ : ត្រូវបានប្រគល់ភារកិច្ចជូនលោក **អ៊ឹម វណ្ណា** ឋានន្តរស័ក្តិអនុមន្ត្រី ថ្នាក់លេខ ១៤ ឱ្យបំពេញមុខងារជាអគ្គនាយករងបច្ចេកទេស នៃក្រសួងអភិវឌ្ឍន៍ជនបទ។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែមេសា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៣៤០ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្តការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់ របស់មន្ត្រីរាជការស៊ីវិល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

ស ម្រេ ច

មាត្រា ១ : ត្រូវបានតែងតាំងអ្នកអង្គម្ចាស់ **ស៊ីសុវត្ថិ ធានុរ័ត្ន** ឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ ១០ ជាអគ្គនាយករងរដ្ឋបាល-ហិរញ្ញវត្ថុ នៃក្រសួងអភិវឌ្ឍន៍ជនបទ។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣៨១ អនក្រ.បក

អនុក្រឹត្យ

ស្ដីពី

ការលុបឈ្មោះមន្ត្រីរាជការក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៩/០៥ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្ដីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច

សម្រេច

មាត្រា១ : ត្រូវបានលុបឈ្មោះលោក **ហ៊ីង ហៀង** ឋានន្តរស័ក្តិអនុមន្ត្រី ថ្នាក់លេខ ៦ ប្រធាននាយកដ្ឋានអប់រំសិក្សាផ្សព្វផ្សាយច្បាប់ ពីក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលនៅក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ដោយមូលហេតុមរណភាព ។

មាត្រា២ : បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣៤៧ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ជូនលោកជំទាវ និង អស់លោក ចំនួន ០៩រូប ដែលមានស្នាដៃល្អ និងគុណបំណាច់ខ្ពស់ក្នុងការជួយកសាងនិងអភិវឌ្ឍន៍មូលដ្ឋាននានា នៅក្នុងខេត្តបាត់ដំបង តាមគោលនយោបាយចតុកោណ របស់រាជរដ្ឋាភិបាល ដូចមានរាយនាមខាងក្រោម :-

ក-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ :

១-ឧកញ៉ា	**ឆោ សុនលី**	ប្រធានក្រុមហ៊ុន
២-ឧកញ៉ា	**ភូ ពុយ**	ប្រធានសភាពាណិជ្ជកម្មខេត្តបាត់ដំបង
៣-លោកជំទាវ	**ង៉ួញ សុខៃ**	អ្នកតំណាងរាស្ត្រមណ្ឌលបាត់ដំបង
៤-លោក	**តែ អ៊ីឆៃ**	អគ្គនាយកក្រុមហ៊ុន អ៊ី ឆៃ

ខ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ សេនា :

-លោក	**អ៊ុច អ៊ាង**	អភិបាលស្រុកថ្មគោល

គ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ អស្សឫទ្ធិ :

១-លោក	**ជា តារា**	មេធាវី
២-លោក	**លឹម ឆាងឡុង**	ប្រធានក្រុមហ៊ុនដឹកជញ្ជូនផ្លូវជាតិលេខ ៥
៣-លោក	**ភាំង ម៉េងហ៊ុយ**	អគ្គនាយកក្រុមហ៊ុន ម៉េងហ៊ុយ
៤-លោក	**ឡុច សារ៉េត**	អគ្គនាយកក្រុមហ៊ុន វិញលី

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។៚

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៣៤៣ អនក្រ. បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ និងមេដាយការងារ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់នាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

សម្រេច

មាត្រា ១ : ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ និងមេដាយការងារ** តាមលំដាប់ថ្នាក់ ជូនឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ចំនួន ៦៣ រូប ដូចមានរាយនាមខាងក្រោម :

ក. មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ :

១- លោកជំទាវ ទ្រី សុខា
២- លោកស្រី រស់ ច័ន្ទផល្លី
៣- លោក សុខ សូរិយា
៤- ឯកឧត្តម ហូ មនោ
៥- ឯកឧត្តម គីម នាន
៦- ឯកឧត្តម តាំ សុខុន
៧- ឯកឧត្តម ងួន ស្រេង
៨- លោក សាមីឌី ស៊ីវឡូនា
៩- ឯកឧត្តម ជា យុពា
១០- ឯកឧត្តម នុត បូពិណ្ណារ៉ា
១១- ឯកឧត្តម ដារ សាវី

ខ. មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ សេនា ៖

១- ឯកឧត្តម រាល ម៉ារ៉ាវី
២- ឯកឧត្តម អៀង សិរីវង្ស
៣- ឯកឧត្តម ថោ ជេដ្ឋា
៤- ឯកឧត្តម សោម សុវុឌ្ឍី
៥- ឯកឧត្តម ឈរ ផល្លី
៦- ឯកឧត្តម ហាក់ សុខហៃ
៧- ឯកឧត្តម ឃឹម រុស្ស៊ីដា
៨- ឯកឧត្តម ជាម ផារី
៩- លោក សំ វណ្ណារ៉ា
១០- លោក ប៊ុន ខេង
១១- លោក ឈន ប៉េងឡេង
១២- លោក ជា សារឿន
១៣- លោក ងួន សំណាង
១៤- លោក អ៊ុក ចន
១៥- លោក ឈួន គឹមឆយ
១៦- លោកស្រី ឈរ ស្រីពីង
១៧- លោកស្រី វ៉ាន់ ចរិយា
១៨- លោក សុខ វិរៈ

គ. មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ អស្សប្ញទ្ធិ ៖

១- ឯកឧត្តម ខេង សិទ្ធិគុណ
២- ឯកឧត្តម សរ ចាន់ធី
៣- លោកស្រី គង់ ម៉ារីយ៍
៤- លោកស្រី មាស វិចិត្រ
៥- លោកស្រី ប៉ក់សម័យ សុរិទ្យានិ
៦- លោកស្រី ញ៉ែម ស៊ីណាត
៧- លោកស្រី ឆេង សុផារី
៨- លោក នី ប៊ុនលី
៩- លោក ឆេង ស៊ីថា
១០- លោក មាស វិបុល
១១- លោក លី ត្រាណិន
១២- លោក ម៉ាត់ សុដារី
១៣- លោក ង៉ោ ពេជ្រ
១៤- លោក ភ័ក្រ វ៉ាន់ឌី
១៥- លោក សោម ប៊ុណ្ណារ៉ា
១៦- លោកស្រី សូ ដារ៉ា
១៧- លោក ភោគ វ៉ាន់ថន
១៨- លោកស្រី ហែម យ៉ានី
១៩- លោកស្រី អ៊ាន អំមរា

ឃ. មេដាយមាសការងារ ៖

១- លោក សោម សុវណ្ណ
២- លោក ឈីវ យីស៊ាង
៣- លោក ម៉ៅ ប៊ុននាង
៤- លោក លឹម ប៊ុនហុក
៥- លោក ភោគ សំអុន
៦- លោក អ៊ុម ស៊ីថន
៧- លោក កេត សាផាន់
៨- លោក ព្រាប ម៉ាណែល

៩- លោក ប៊ុន ថន
១០- លោក វ៉ា សារីទ្ធ
១១- លោក នឹម វីរៈ
១២- លោក ម៉ែន ម៉ុន
១៣- លោក សាន កល់
១៤- លោក គ្រួយ ស៊ីណន
១៥- លោក សុខ សុវណ្ណ

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងនាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ឆ្នាំ ២០០៧

ហ៊ុន សែន

<u>**កន្លែងទទួល**</u> :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និងមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...៣៤៤...អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** ប្រគេននិងផ្តល់ជូនសប្បុរសជន ចំនួន ១៦រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមជួយកសាងព្រះវិហារ និង សមិទ្ធផលនានាជាច្រើនទៀត នៅ***វត្តជម្ពូវ័ន*** ហៅ ***វត្តចោយសំរោង*** ឃុំតាពូង និង ***វត្តត្រ័យរតនសុខារាម*** ហៅ ***វត្តជណ្តើរស្វា*** ឃុំគោកឃ្មុំ ស្រុកថ្មគោល ខេត្តបាត់ដំបង ដូចមានរាយព្រះនាមនិងនាមខាងក្រោម :-

ក_មេដាយមាសស្ថាបនាជាតិ :

១-លោក **ឃាច ហ៊ី** សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក . ថវិកា ចំនួន ៣៤.៥៦០ ដុល្លារ

២-លោកស្រី **ទិត សាវ៉ាន** សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក ថវិកា ចំនួន ២៤.៥៦០ ដុល្លារ

៣-លោកស្រី **ជាម លុយ** សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក ថវិកាចំនួន ២៥.១១០.៦៣ ដុល្លារ

៤-លោកស្រី **រ័ត្ន ចំណី** សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក ថវិកាចំនួន ២៤.៩៣៩.១៣ ដុល្លារ

៥-លោក **អ៊ូច សម្បូរ** និងលោកស្រី **ឡៅស ខៀប** សប្បុរសជននៅខេត្តបាត់ដំបង ថវិកាចំនួន ១៤.៥៦០ ដុល្លារ

៦-លោក **ប៊ិម ស៊ុន** និងលោកស្រី **ថ្មី សោភ័ណ** សប្បុរសជននៅខេត្តបាត់ដំបង ថវិកាចំនួន ១០.១៩៨,១៣ ដុល្លារ

៧-លោក **គ្រី លន់តែ** និងលោកស្រី **ជា សុខ** សប្បុរសជននៅខេត្តបាត់ដំបង ថវិកាចំនួន ១៦.២៣៧,៥០ ដុល្លារ

ខ_មេដាយប្រាក់ស្ថាបនាជាតិ :

១-ព្រះតេជគុណជយានន្ទោ **ជួន ចិន្តា** ចៅអធិការវត្តជម្ពូវ័ន បច្ច័យ ចំនួន ៥.០០០ ដុល្លារ

២-លោកស្រី **ហ៊ី ហួយ** សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក ថវិកា ចំនួន ៥.០០០ ដុល្លារ

៣-លោកស្រី **ជាម ឡេង** សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក ថវិកា ចំនួន ៧.០០០ ដុល្លារ

៤-លោក **ទិត គ្លីន** សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក ថវិកា ចំនួន ៦.៣៤០ ដុល្លារ

៥-លោក **ថម ស្រ៊ីម** សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក ថវិកា ចំនួន ៦.១៦៥ ដុល្លារ

៦-លោកស្រី **យូ ឆាត់** សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក ថវិកា ចំនួន ៧.៤៤០ ដុល្លារ

៧-លោក **កែវ ខាំ** ប្រធានអាចារ្យវត្តជម្ពូវ័ន ថវិកា ចំនួន ៥.០០០ ដុល្លារ

គ.មេដាយសេរីវឌ្ឍនាជាតិ :

១-លោក **ម៉ើន ឡឿន ហៅ វ៉េម** សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក ថវិកា ចំនួន ៤.០២០ ដុល្លារ

២-លោកស្រី **មាស់ គីមឆៃ** សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក ថវិកា ចំនួន ៤.៥០០ ដុល្លារ

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តបាត់ដំបង ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៧

ហ៊ុន សែន

<u>កន្លែងទទួល :</u>

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៤១ អនក្រ.

សេចក្តីសម្រេច
ស្តីពី
ការបង្កើតគណៈកម្មការវាយតម្លៃ និងរៀបចំបែងចែកដី ចំពោះគម្រោងអភិវឌ្ឍន៍របស់ក្រុមហ៊ុន កំពត ផត

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែសីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- យោងតាមការចាំបាច់

ស ម្រេ ច

ប្រការ ១.-

ត្រូវបានបង្កើតគណៈកម្មការវាយតម្លៃ និងរៀបចំបែងចែកដី ចំពោះគម្រោងអភិវឌ្ឍន៍របស់ក្រុមហ៊ុនកំពត ផត ដែលមានសមាសភាពដូចតទៅ :

១- ឯកឧត្តម	ម៉ុន ឫទ្ធិ	រដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី	ប្រធាន
២- ឯកឧត្តម	ង៉ោក វ៉ាម៉ុន	រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	អនុប្រធាន

៣- ឯកឧត្តម	ហ៊ុន ម៉ាណែត	ទីប្រឹក្សា និងជានាយករងខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី	សមាជិក
៤- ឯកឧត្តម	លឹម ទាន់	អគ្គនាយកសុរិយោដី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់	សមាជិក
៥- ឯកឧត្តម	គុំ សារ៉ែន	អគ្គនាយក ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ	សមាជិក
៦-ឯកឧត្តម	ឡុញ ម៉ារិល	អគ្គនាយកបច្ចេកទេស ក្រសួងបរិស្ថាន	សមាជិក
៧- ឯកឧត្តម	ខួន នៅ	អគ្គនាយកបច្ចេកទេស ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល	សមាជិក
៨- ឯកឧត្តម	ជា ទុន្នី	អគ្គលេខាធិការរង គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា	សមាជិក
៩- ឯកឧត្តម	ថាច់ ឃន	អភិបាលខេត្តកំពត	សមាជិក

ប្រការ ២.-

គណៈកម្មការវាយតម្លៃ និងរៀបចំបែងចែកដី មានភារកិច្ចដូចតទៅ :

១- ពិនិត្យគ្រប់ជ្រុងជ្រោយលើនីតិវិធី និងច្បាប់ជាធរមាន ក្នុងការវាយតម្លៃ និង រៀបចំបែងចែកដីថ្មី នៃគម្រោងអភិវឌ្ឍន៍របស់ក្រុមហ៊ុនកំពត ផត ។

២- ពិនិត្យគ្រប់ទិដ្ឋភាពចំពោះហេតុប៉ះពាល់ បរិស្ថាន សង្គម-សេដ្ឋកិច្ច ក្នុងតំបន់ និងបញ្ហានានាដែលអាចកើតមានជាយថាហេតុ ។

៣- ធ្វើសេចក្តីរាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាលអំពីលទ្ធផលនៃការប្រជុំ និងការចុះត្រួតពិនិត្យជាក់ស្តែង ដើម្បីសុំការសម្រេច ។

ប្រការ ៣.-

សមាជិកគណៈកម្មការនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

ប្រការ ៤.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដី និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។/.

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ៤*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ០៥ សរណន

សារាចរណែនាំ

ស្តីពី

ការចាត់តាំងខួបអនុស្សាវរីយ៍លើកទី ១២១

នៃទិវាពលកម្មអន្តរជាតិ ថ្ងៃទី ១ ខែ ឧសភា ឆ្នាំ ២០០៧

ទិវាពលកម្មអន្តរជាតិ ថ្ងៃទី ១ ខែ ឧសភា គឺជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រនៃចលនាកម្មករអន្តរជាតិដែលចាប់ផ្តើមនា ឆ្នាំ ១៨៨៦ ក្នុងគោលបំណងធ្វើឱ្យប្រសើរឡើងនូវស្ថានភាពនៃលក្ខខណ្ឌការងារ និងជីវភាពរស់នៅរបស់ប្រជាពលករ ។ នៅកម្ពុជា ***ទិវាពលកម្មអន្តរជាតិ ថ្ងៃទី ១ ខែ ឧសភា*** ត្រូវបានប្រារព្ធជារៀងរាល់ឆ្នាំតាំងពីឆ្នាំ ១៩៧៩ ហើយមកដល់បច្ចុប្បន្ននេះ រាជរដ្ឋាភិបាលកម្ពុជា ក៏បានកំណត់យកថ្ងៃទី ១ ខែ ឧសភា គឺជាថ្ងៃបុណ្យការងាររបស់ពលករកម្ពុជា និងជាថ្ងៃឈប់សំរាករបស់មន្ត្រីរាជការ ក៏ដូចជាកម្មករនិយោជិត ។ ជារៀងរាល់ឆ្នាំ មានស្ថាប័នរដ្ឋ និងសហគ្រាស គ្រឹះស្ថានឯកជនជាច្រើនបានរៀបចំអបអរសាទរ និងប្រារព្ធទិវានេះ ក្នុងបរិយាកាសសប្បាយរីករាយ និងសាមគ្គីភាពគួរឱ្យកត់សម្គាល់ ។

ឆ្នាំ ២០០៧ នេះ យើងទាំងអស់គ្នានៅតែបន្តយក ***ទិវាពលកម្មអន្តរជាតិ ថ្ងៃទី ១ ខែ ឧសភា*** ជាថ្ងៃប្តេជ្ញាចិត្តលើកកំពស់ការអនុវត្តលក្ខខ័ណ្ឌការងារ និងធានាសិទ្ធិប្រយោជន៍កម្មករ និយោជិតតាមច្បាប់ស្តីពីការងារ ជាពិសេសការអនុវត្តន៍ស្មារតីអនុសញ្ញាអន្តរជាតិខាងការងារចំនួន ១៣ ក្នុងនោះមានអនុសញ្ញាស្នូលចំនួន ៨ ដែលព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័នរួចមកហើយ ។ ទន្ទឹមនឹងនេះ យើងទាំងអស់គ្នាក៏ត្រូវកំណត់យកទិវានេះ ជាថ្ងៃប្តេជ្ញាចិត្តក្នុងការបង្កើនគុណភាពផលិតផលសម្រាប់ការប្រកួតប្រជែង ក៏ដូចជាការរក្សាចិរភាពសហគ្រាសគ្រឹះស្ថាន ដើម្បីការអភិវឌ្ឍន៍ជាតិ និងការលើកកំពស់ជីវភាពប្រជាពលរដ្ឋ ។

អាស្រ័យហេតុនេះ ដើម្បីរៀបចំការប្រារព្ធខួបលើកទី ១២១ នៃ ***ទិវាពលកម្មអន្តរជាតិ ថ្ងៃទី ១ ឧសភា ឆ្នាំ ២០០៧*** នេះ ប្រព្រឹត្តទៅបានល្អ រាជរដ្ឋាភិបាលកម្ពុជាសូមធ្វើការណែនាំដូចខាងក្រោមនេះ ÷

១. ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈត្រូវចេញសេចក្តីជូនដំណឹងដើម្បីណែនាំអំពីការឈប់សម្រាក និងបំផុសការជួបសំណេះសំណាល ការជួបជុំជប់លៀងកំសាន្តសប្បាយ ការដើរកំសាន្តតាម

រូបភាព និងលទ្ធភាពរៀងៗខ្លួនរបស់សហគ្រាស គ្រឹះស្ថានសំដៅបង្កបរិយាកាសសាមគ្គីភាព ភាតរភាព រវាងកម្មករនិយោជិត និងនិយោជក ។ ថ្នាក់ដឹកនាំក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈត្រូវជ្រើសរើសរោងចក្រមួយជានិមិត្តរូប ដើម្បីចូលរួមកម្មវិធីកំសាន្តសប្បាយរីករាយ និងធ្វើការសំណេះសំណាលជាមួយកម្មករនិយោជិត ។

២. ក្រសួងព័ត៌មានត្រូវណែនាំប្រព័ន្ធឃោសនារបស់រដ្ឋ និងឯកជនទទួលផ្សព្វផ្សាយ *សារលិខិតរបស់សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ក្នុងឱកាសខួបអនុស្សាវរីយ៍លើកទី ១២១ នៃទិវាពលកម្មអន្តរជាតិ ថ្ងៃទី ១ ខែ ឧសភា ឆ្នាំ ២០០៧* ឱ្យបានទូលំទូលាយ ។

៣. ក្រសួងមហាផ្ទៃ អគ្គស្នងការនគរបាលជាតិ បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស អាជ្ញាធរខេត្តក្រុង និងស្ថាប័នពាក់ព័ន្ធទាំងអស់ត្រូវតែមានការណែនាំកម្លាំងសមត្ថកិច្ចរបស់ខ្លួន ក្នុងការថែរក្សាសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ ក្នុងឱកាស *ទិវាពលកម្មអន្តរជាតិ ថ្ងៃទី ១ ខែ ឧសភា* ឆ្នាំ ២០០៧ នេះ ។

៤. សាលាខេត្ត-ក្រុងត្រូវចាត់ចែងការចងបដាពាក្យស្លោកនៅតាមដងវិថីសំខាន់ៗ ជាពិសេសនៅក្នុងរាជធានីភ្នំពេញ ។ ដោយឡែក ក្រសួងស្ថាប័ន អង្គភាពរដ្ឋ និងសហគ្រាសគ្រឹះស្ថានឯកជនគ្រប់ខេត្ត-ក្រុងត្រូវចងបដាពាក្យស្លោកថា *«អបអរសាទរខួបអនុស្សាវរីយ៍លើកទី ១២១ នៃទិវាពលកម្មអន្តរជាតិ ថ្ងៃទី ១ ខែ ឧសភា ឆ្នាំ ២០០៧»* នៅពីមុខអគាររៀងៗខ្លួន ។

រាជរដ្ឋាភិបាលកម្ពុជាសូមអំពាវនាវដល់អង្គការវិជ្ជាជីវៈ សមាគម និងប្រជាពលរដ្ឋទាំងអស់ សូមចូលរួមអបអរសាទរ *ទិវាពលកម្មអន្តរជាតិ ថ្ងៃទី ១ ខែ ឧសភា ឆ្នាំ ២០០៧* ក្នុងសេចក្តីរីករាយ សាមគ្គីភាព និងភាតរភាព ដើម្បីឱ្យស័ក្តិសមជាបុណ្យការងាររបស់ប្រទេសជាតិយើង។

ទទួលបានសារាចរណែនាំនេះ សូមឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំគ្រប់ជាន់ថ្នាក់នៃក្រសួង ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរគ្រប់ខេត្ត-ក្រុង រៀបចំចាត់តាំងអនុវត្តប្រកបដោយស្មារតីទទួលខុសត្រូវ និងមានប្រសិទ្ធភាពខ្ពស់ ។

រាជធានីភ្នំពេញ ថ្ងៃទី១២ ខែ មេសា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>កន្លែងទទួល</u>

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *គ្រប់ក្រសួង-រដ្ឋលេខាធិការដ្ឋាន-ស្ថាប័ន និងខេត្ត-ក្រុង*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

❋❋❋❋❋❋❋

ក្រសួងអប់រំ យុវជន និង កីឡា

លេខៈ ៣៩៦ អយក.ប្រក

[illegible]
ថ្ងៃទី ៣០ ខែ ៤ ឆ្នាំ២០០៧

ប្រកាស

ស្តីពីការពង្រីកសាលារៀនចំណេះទូទៅឯកជន “ សាលាអន្តរជាតិញូវយ៉ក ”
ស្ថិតនៅក្នុង សង្កាត់ បឹងកក់២ ខណ្ឌ ទួលគោក រាជធានីភ្នំពេញ

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ០៧០៤-១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ១៩៩៤ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស-រកត ០៧៩៦-៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ ១២ឆ្នាំ
- បានឃើញអនុក្រឹត្យ លេខ ២១ អនក្រ-បក ចុះថ្ងៃទី២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យ លេខ ១៨ អនក្រ ចុះថ្ងៃទី ១៥ មិថុនា ១៩៩២ ស្តីពីការបើកសាលារៀនចំណេះទូទៅឯកជន
- យោងលិខិតស្នើសុំរបស់ លោក ជា សុខឃាង ចុះថ្ងៃទី ២៦ កញ្ញា ២០០៦ ដោយមានយោបល់ឯកភាពពីមន្ទីរអប់រំ យុវជន និង កីឡា រាជធានីភ្នំពេញ
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ

សម្រេច

ប្រការ១ : អនុញ្ញាតឱ្យពង្រីកសាលាចំណេះទូទៅឯកជន “ *សាលាអន្តរជាតិញូវយ៉ក* ” ចាប់ពីកំរិត បឋមសិក្សា ដល់ មធ្យមសិក្សាទុតិយភូមិ ស្ថិតនៅក្នុង សង្កាត់ បឹងកក់២ ខណ្ឌ ទួលគោក រាជធានីភ្នំពេញ ចាប់ពីឆ្នាំសិក្សា ២០០៦-២០០៧ តទៅ។

ប្រការ២ : សាលារៀនឯកជន **សាលាអន្តរជាតិញូវយ៉ក** ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់មន្ទីរអប់រំ យុវជន និង កីឡា រាជធានីភ្នំពេញ និងត្រូវអនុវត្តកម្មវិធីសិក្សាតាមការអនុញ្ញាតរបស់ក្រសួងអប់រំ យុវជន និង កីឡា។

ប្រការ៣ : **លោក ជា សុខឃាង** ជានាយកសាលាត្រូវដឹកនាំ ចាត់តាំង គ្រប់គ្រងសាលារៀនទាំងផ្នែករដ្ឋបាល និងផ្នែកបច្ចេកទេស ព្រមទាំងទទួលខុសត្រូវក្នុងការងារ :

- ជ្រើសរើសគ្រូបង្រៀនដែលមានសមត្ថភាពគរុកោសល្យសមស្រប។
- ជ្រើសរើសសិស្សឱ្យចូលរៀន។
- ធានាដំណើរការបង្រៀន និងរៀនឱ្យបានល្អ។
- គោរព និងអនុវត្តសារាចរ សេចក្តីណែនាំរបស់ក្រសួងអប់រំ យុវជន និង កីឡា។
- ធានាឱ្យមានសុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គម។
- រាយការណ៍រាល់សកម្មភាពសិក្សាជូនមន្ទីរអប់រំ យុវជន និង កីឡា រាជធានីភ្នំពេញ តាមកាលកំណត់ ។

ប្រការ៤ : ក្រសួងអប់រំ យុវជន និង.កីឡា មានសិទ្ធិធ្វើអធិការកិច្ច ត្រួតពិនិត្យ ហើយមានសិទ្ធិបិទ ប្រសិនបើសាលារៀននេះអនុវត្តខុសពីគោលការណ៍អប់រំរបស់រដ្ឋ ។

ប្រការ៥ : អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និង កីឡា មន្ទីរអប់រំ យុវជន និង កីឡា រាជធានីភ្នំពេញ និងនាយកសាលារៀនសាមីមានភារកិច្ចរៀង១ខ្លួនអនុវត្តប្រកាសនេះ ។

ភ្នំពេញ, ថ្ងៃទី១៦ ខែ មីនា ឆ្នាំ២០០៧

ជ. ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំយុវជននិងកីឡា

រដ្ឋលេខាធិការ

អ៊ឹក_ទ៉ាំង

<u>កន្លែងទទួល:</u>

- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
  "ដើម្បីជ្រាបជាពត៌មាន"
- -សាលាក្រុងភ្នំពេញ "ដើម្បីជាពត៌មាន"
- -ដូចប្រការ៥
- -កាលប្បវត្តិ-ឯកសារ នា.មធទ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

❀❀❀❀❀❀❀

ក្រសួងអប់រំ យុវជន និង កីឡា

លេខ: ៤៩៧/អយក.ប្រក

ថ្ងៃទី ៣០ ខែ ៤ ឆ្នាំ២០០៧

ប្រកាស

ស្តីពីការប្តូរឈ្មោះ អនុវិទ្យាល័យ " **ជន្លង់ម្លូ** " ទៅជា

អនុវិទ្យាល័យ " **ហ៊ុន សែន ជន្លង់ម្លូ** "

ស្ថិតនៅក្នុង សង្កាត់ ភ្លើងឆេះរទេះ ខណ្ឌ ដង្កោ រាជធានីភ្នំពេញ

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ០៧០៤-១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ១៩៩៤ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស-រកត ០៧៩៦-៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ ១២ឆ្នាំ
- បានឃើញអនុក្រឹត្យ លេខ ២១ អនក្រ-បក ចុះថ្ងៃទី២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទម ចុះថ្ងៃទី ០២ មេសា ១៩៨៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកំរិត១- កំរិត២
- យោងលិខិតស្នើសុំប្តូរឈ្មោះលេខ ១១ លស.អនុវិ-ជម ចុះថ្ងៃទី ២១ កុម្ភៈ ២០០៧ ដោយមានយោបល់ឯកភាពពី មន្ទីរអប់រំ យុវជន និង កីឡា រាជធានីភ្នំពេញ
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ

សំរេច

ប្រការ ១ : អនុញ្ញាតឱ្យប្តូរឈ្មោះ អនុវិទ្យាល័យ " **ជន្លង់ម្លូ** " បច្ចុប្បន្ន ទៅជា អនុវិទ្យាល័យ " **ហ៊ុន សែន ជន្លង់ម្លូ** " ស្ថិតនៅក្នុង សង្កាត់ ភ្លើងឆេះរទេះ ខណ្ឌ ដង្កោ រាជធានីភ្នំពេញ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ប្រការ ២ : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៣ : អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និង កីឡា មន្ទីរអប់រំ យុវជន និង កីឡា រាជធានីភ្នំពេញ និងនាយកអនុវិទ្យាល័យសាមីមានភារកិច្ច រៀងៗខ្លួនអនុវត្តប្រកាសនេះ ។

ភ្នំពេញ ថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ២០០៧

បណ្ឌិត កុល ពេញ

កន្លែងទទួល:

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ " ដើម្បីជ្រាបជាពត៌មាន "
- សាលារាជធានីភ្នំពេញ "ដើម្បីជាពត៌មាន"
- ដូចប្រការ៣
- កាលប្បវត្តិ-ឯកសារ ទា.មចទ

Ith Chetha/RenameSchool doc

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា

លេខ: ៤៤៨ អយក.ប្រក

ចម្លងត្រឹមត្រូវ

ថ្ងៃទី ៣០ ខែ ៤ ឆ្នាំ២០០៧

ប្រកាស

ស្តីពីការពង្រីកសាលារៀនចំណេះទូទៅឯកជន " សាលារៀន អន្តរទ្វីបអាមេរិកកាំង " ស្ថិតនៅក្នុង សង្កាត់ ទួលស្វាយព្រៃទី១ ខណ្ឌ ចំការមន ក្រុង ភ្នំពេញ

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ០៧០៤-១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ១៩៩៤ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស-រកត ០៧៩៦-៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ ១២ឆ្នាំ
- បានឃើញអនុក្រឹត្យ លេខ ២១ អនក្រ-បក ចុះថ្ងៃទី២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យ លេខ ១៨ អនក្រ ចុះថ្ងៃទី ១៥ មិថុនា ១៩៩២ ស្តីពីការបើកសាលារៀនចំណេះទូទៅឯកជន
- យោងលិខិតស្នើសុំរបស់ លោក សាស្ត្រ. វេជ្ជ ឌួច មេងលី ចុះថ្ងៃទី ០៧ ធ្នូ ២០០៦ ដោយមានយោបល់ឯកភាពពីមន្ទីរអប់រំ យុវជន និង កីឡា និងអភិបាល ក្រុង ភ្នំពេញ
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ

សម្រេច

ប្រការ១ : អនុញ្ញាតឱ្យពង្រីកសាលាចំណេះទូទៅឯកជន " ***សាលារៀន អន្តរទ្វីបអាមេរិកកាំង*** " ចាប់ពីកំរិត បឋមសិក្សា ដល់ មធ្យមសិក្សាទុតិយភូមិ ស្ថិតនៅក្នុង សង្កាត់ ទួលស្វាយព្រៃទី១ ខណ្ឌ ចំការមន ក្រុង ភ្នំពេញ ចាប់ពីឆ្នាំសិក្សា ២០០៦-២០០៧ តទៅ ។

ប្រការ២ : សាលារៀនឯកជន **សាលារៀន អន្តរទ្វីបអាមេរិកកាំង** ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់មន្ទីរអប់រំ យុវជន និង កីឡា ក្រុង ភ្នំពេញ និងត្រូវ អនុវត្តកម្មវិធីសិក្សាតាមការអនុញ្ញាតរបស់ក្រសួងអប់រំ យុវជន និង កីឡា ។

ប្រការ៣ : **លោក សាស្ត្រ. វេជ្ជ ឌួច មេងលី** ជានាយកសាលាត្រូវដឹកនាំ ចាត់ចែង គ្រប់គ្រងសាលារៀនទាំងផ្នែករដ្ឋបាល និងផ្នែកបច្ចេកទេស ព្រមទាំង ទទួលខុសត្រូវក្នុងការងារ :

- ជ្រើសរើសគ្រូបង្រៀនដែលមានសមត្ថភាពគរុកោសល្យសមស្រប ។
- ជ្រើសរើសសិស្សឱ្យចូលរៀន ។
- ធានាដំណើរការបង្រៀន និងរៀនឱ្យបានល្អ ។
- គោរព និងអនុវត្តសារាចរ សេចក្តីណែនាំរបស់ក្រសួងអប់រំ យុវជន និង កីឡា ។
- ធានាឱ្យមានសុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គម ។
- រាយការណ៍រាល់សកម្មភាពសិក្សាជូនមន្ទីរអប់រំ យុវជន និង កីឡា ក្រុង ភ្នំពេញ តាមកាលកំណត់ ។

ប្រការ៤ : ក្រសួងអប់រំ យុវជន និង កីឡា មានសិទ្ធិធ្វើអធិការកិច្ច ត្រួតពិនិត្យ ហើយមានសិទ្ធិបិទ ប្រសិនបើសាលារៀននេះអនុវត្តខុសពី គោលការណ៍អប់រំរបស់រដ្ឋ។

ប្រការ៥ : អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និង កីឡា មន្ទីរអប់រំ យុវជន និង កីឡា ក្រុង ភ្នំពេញ និងនាយកសាលារៀនសាមីមាន ភារកិច្ចរៀង១ខ្លួនអនុវត្តប្រកាសនេះ។

ភ្នំពេញ ថ្ងៃទី២៧ ខែ មីនា ឆ្នាំ២០០៧

បណ្ឌិត កុល ប៉ាង

កន្លែងទទួល:

- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
  "ដើម្បីជ្រាបជាពត៌មាន"
- សាលាក្រុង ភ្នំពេញ "ដើម្បីជាពត៌មាន"
- ដូចប្រការ៥
- កាលប្បវត្តិ-ឯកសារ នា.មចទ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

❀❀❀❀❀❀❀

ក្រសួងអប់រំ យុវជន និង កីឡា

លេខ: ៤៤៩ អយក.ប្រក

ប្រកាស

ស្តីពីការពង្រីកអនុវិទ្យាល័យ " **ហ៊ុន សែន កំពង់សិលា** " ទៅជាវិទ្យាល័យ " **ហ៊ុន សែន កំពង់សិលា** "
ស្ថិតនៅក្នុង ឃុំ កំពង់សិលា ស្រុក កំពង់សិលា ខេត្ត កោះកុង

ទទួលបានថ្ងៃទី ៣០ ខែ ៤ ឆ្នាំ20០៧

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ០៧០៤-១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ១៩៩៤ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស-រកត ០៧៩៦-៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ ១២ឆ្នាំ
- បានឃើញអនុក្រឹត្យ លេខ ២១ អនក្រ-បក ចុះថ្ងៃទី២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទម ចុះថ្ងៃទី ០២ មេសា ១៩៨៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកំរិត១- កំរិត២
- យោងលិខិតស្នើសុំរបស់សហគមន៍ ឃុំ កំពង់សិលា ស្រុក កំពង់សិលា ចុះថ្ងៃទី ១០ វិច្ឆិកា ២០០៦ ដោយមានយោបល់ ឯកភាពពីមន្ទីរអប់រំ យុវជន និង កីឡា និង អភិបាល ខេត្ត កោះកុង
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ

សំរេច

ប្រការ ១ : អនុញ្ញាតឱ្យពង្រីកអនុវិទ្យាល័យ " **ហ៊ុន សែន កំពង់សិលា** " បច្ចុប្បន្ន ទៅជា វិទ្យាល័យ " **ហ៊ុន សែន កំពង់សិលា** " ស្ថិតនៅក្នុង ឃុំ កំពង់សិលា ស្រុក កំពង់សិលា ខេត្ត កោះកុង ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ប្រការ ២ : វិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ព្រមទាំងបុគ្គលិកផ្សេងៗមួយចំនួនទៀតតាមអង្គការលេខនៃវិទ្យាល័យ ។

ប្រការ ៣ : នាយក-នាយករង និងបុគ្គលិកសិក្សានៃវិទ្យាល័យ មានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍របស់រដ្ឋ ។

ប្រការ ៤ : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៥ : អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និង កីឡា មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត កោះកុង នាយកវិទ្យាល័យសាមីមានភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ។

ភ្នំពេញ, ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ២០០៧

បណ្ឌិត កុល ប៉េង

កន្លែងទទួល:
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ " ដើម្បីជ្រាបជាពតិមាន "
- សាលា ខេត្ត កោះកុង "ដើម្បីជាពតិមាន"
- ដូចប្រការ៥
- កាលប្បវត្តិ-ឯកសារ នា.មចទ

Ith Chetha/ Increase School doc

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា

លេខៈ ៤៦០ អយក.ប្រក

លិខិតចូល
ថ្ងៃទី ៣០ ខែ ៤ ឆ្នាំ២០០៧

ប្រកាស

ស្តីពីការប្តូរឈ្មោះ វិទ្យាល័យ "**អូន ព័ន្ធមុនីវត្ត វិហារសួគ៌**" ទៅជា

វិទ្យាល័យ "**វិហារសួគ៌**"

ស្ថិតនៅក្នុង ឃុំ វិហារសួគ៌ ស្រុក ខ្សាច់កណ្តាល ខេត្ត កណ្តាល

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ០៧០៤-១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ១៩៩៤ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស-រកត ០៧៩៦-៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ ១២ឆ្នាំ
- បានឃើញអនុក្រឹត្យ លេខ ២១ អនក្រ-បក ចុះថ្ងៃទី២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទម ចុះថ្ងៃទី ០២ មេសា ១៩៨៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកម្រិត១- កម្រិត២
- យោងលិខិតស្នើសុំរបស់សហគមន៍ ឃុំ វិហារសួគ៌ ស្រុក ខ្សាច់កណ្តាល ចុះថ្ងៃទី ១២ មករា ២០០៧ ដោយមានយោបល់ឯកភាពពីមន្ទីរអប់រំ យុវជន និង កីឡា និង អភិបាល ខេត្ត កណ្តាល
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ

សម្រេច

ប្រការ ១ : អនុញ្ញាតឱ្យប្តូរឈ្មោះ វិទ្យាល័យ "**អូន ព័ន្ធមុនីវត្ត វិហារសួគ៌**" បច្ចុប្បន្ន ទៅជា វិទ្យាល័យ "**វិហារសួគ៌**" ស្ថិតនៅក្នុង ឃុំ វិហារសួគ៌ ស្រុក ខ្សាច់កណ្តាល ខេត្ត កណ្តាល ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ប្រការ ២ : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៣ : អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និង កីឡា មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត កណ្តាល និងនាយកវិទ្យាល័យ សាមីមានភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ។

ភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០៧

បណ្ឌិត កុល ពាំង

កន្លែងទទួលៈ

- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ "ដើម្បីជ្រាបជាពត៌មាន"
- សាលាខេត្ត កណ្តាល "ដើម្បីជាពត៌មាន"
- ដូចប្រការ៣
- កាលប្បវត្តិ-ឯកសារ នា.មចទ

...th Chetha/Renam School.doc

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា

លេខ: ៤៦១ អយក.ប្រក

ចំលងត្រឹមត្រូវ
ថ្ងៃទី ១១ ខែ ៤ ឆ្នាំ២០០៧

ប្រកាស

ស្តីពីការបើកអនុវិទ្យាល័យ " **ស្វាយរលំ** "

ស្ថិតនៅក្នុង ឃុំ ស្វាយរលំ ស្រុក ស្អាង ខេត្ត កណ្តាល

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ០៧០៤-១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ១៩៩៤ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស-រកត ០៧៩៦-៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ ១២ឆ្នាំ
- បានឃើញអនុក្រឹត្យ លេខ ២១ អនក្រ-បក ចុះថ្ងៃទី២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទម ចុះថ្ងៃទី ០២ មេសា ១៩៨៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកម្រិត១- កម្រិត២
- យោងលិខិតស្នើសុំរបស់សហគមន៍ ឃុំ ស្វាយរលំ ស្រុក ស្អាង ចុះថ្ងៃទី ០១ កញ្ញា ២០០៦ ដោយមានយោបល់ ឯកភាពពី មន្ទីរអប់រំ យុវជន និង កីឡា និង អភិបាល ខេត្ត កណ្តាល
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ

សម្រេច

ប្រការ ១ : អនុញ្ញាតឱ្យបើកអនុវិទ្យាល័យដែលមានឈ្មោះថា : អនុវិទ្យាល័យ " **ស្វាយរលំ** " ស្ថិតនៅក្នុង ឃុំ ស្វាយរលំ ស្រុក ស្អាង ខេត្ត កណ្តាល ចាប់ពីឆ្នាំសិក្សា ២០០៦-២០០៧ តទៅ ។

ប្រការ ២ : អនុវិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ព្រមទាំងបុគ្គលិកផ្សេងៗមួយចំនួនទៀតតាមអង្គការលេខនៃអនុវិទ្យាល័យ ។

ប្រការ ៣ : នាយក-នាយករង និងបុគ្គលិកសិក្សានៃអនុវិទ្យាល័យ មានសិទ្ធិទទួលប្រាក់បំណាច់ការកិច្ចតាមគោលការណ៍របស់រដ្ឋ ។

ប្រការ ៤ : អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និង កីឡា មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត កណ្តាល និងនាយកអនុវិទ្យាល័យសាមី មានភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ។

ភ្នំពេញ, ថ្ងៃទី ០៤ ខែ មេសា ឆ្នាំ២០០៧

កុល ពាង

កន្លែងទទួល:

- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ " ដើម្បីជ្រាបជាពត៌មាន "
- សាលាខេត្ត កណ្តាល "ដើម្បីជាពត៌មាន"
- ដូចប្រការ៤
- កាលប្បវត្តិ-ឯកសារ ន.មចទ

lth Chetha/NewSchool.doc

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

❀❀❀❀❀❀❀

ក្រសួងអប់រំ យុវជន និង កីឡា

លេខ: ៤៦៧ អយក.ប្រក

[illegible]
ថ្ងៃទី ៣០ ខែ ៤ ឆ្នាំ២០០៧

ប្រកាស

ស្តីពីការពង្រីកអនុវិទ្យាល័យ " **ហ្វូរពន្លឺសិល្បៈ** " ទៅជាវិទ្យាល័យ " **ហ្វូរពន្លឺសិល្បៈ** " ស្ថិតនៅក្នុង ឃុំ អូរចារ ស្រុក បាត់ដំបង ខេត្ត បាត់ដំបង

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ០៧០៤-១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ១៩៩៤ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស-រកត ០៧៩៦-៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ ១២ឆ្នាំ
- បានឃើញអនុក្រឹត្យ លេខ ២១ អនក្រ-បក ចុះថ្ងៃទី២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទម ចុះថ្ងៃទី ០២ មេសា ១៩៨៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកំរិត១- កំរិត២
- យោងលិខិតស្នើសុំរបស់សហគមន៍ ឃុំ អូរចារ ស្រុក បាត់ដំបង ចុះថ្ងៃទី ០៣ កក្កដា ២០០៦ ដោយមានយោបល់ ឯកភាពពី មន្ទីរអប់រំ យុវជន និង កីឡា និង អភិបាល ខេត្ត បាត់ដំបង
